ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីប្រកាសព័ត៌មាន

# ស្តីពី

# ការប្រារព្ធខួបអនុស្សាវរីយ៍លើកទី១៣៩ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា

យោងសារាចរណែនាំលេខ០៦ សរ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៥ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការរៀបចំខួបអនុស្សាវរីយ៍លើកទី១៣៩ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៥ ក្រោមប្រធានបទ **"រួមគ្នាដើម្បីការងារសមរម្យ និងកំណើនប្រកបដោយចីរភាពនិងភាពធន់"** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនបងប្អូនកម្មករនិយោជិត និយោជក និងសាធារណជន ជ្រាបអំពីការប្រារព្ធខួបអនុស្សាវរីយ៍លើកទី១៣៩ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា ដូចខាងក្រោម៖

- រោងចក្រ សហគ្រាសបានឈប់សម្រាក ដើម្បីចូលរួមអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣៩ នៃទិវាពលកម្មអន្តរជាតិ ក្នុងនោះមានរោងចក្រចំនួន ៤១ បានរៀបចំកម្មវិធីអបអរសាទរទិវាពលកម្មអន្តរជាតិ ១ ឧសភា ដែលមានកម្មករនិយោជិតចូលរួមប្រមាណជាង ១ម៉ឺននាក់

- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត បានធ្វើជាសេនាធិការជូនរដ្ឋបាលរាជធានី ខេត្ត ក្នុងការរៀបចំអបអរសាទរទិវាពលកម្មអន្តរជាតិ ១ ឧសភា ទៅតាមទីកន្លែង និងកម្មវិធីរៀងៗខ្លួនប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាល

- នៅព្រឹកថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៥ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ សេដ្ឋកិច្ចក្រៅប្រព័ន្ធ និងសមាគមបុគ្គលិកសិក្សាចំនួន ៥ ៦៩៦នាក់

- នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៥ **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានជួបសំណេះសំណាលជាមួយកម្មករនិយោជិតចំនួន ២ ៧១០នាក់ ក្នុងតំបន់សេដ្ឋកិច្ចពិសេសខេត្តស្វាយរៀង

- នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៥ មានរៀបចំអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣៩ នៃទិវាពលកម្មអន្តរជាតិ ចំនួន ៤ទីតាំង ដូចខាងក្រោម៖

  - នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ បានជួបសំណេះសំណាលជាមួយមន្ត្រីរាជការ បុគ្គលិក កម្មករនិយោជិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី**



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- នៅទីតាំងមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ, សួនច្បារកោះនរាហ៍, សួនច្បារក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានរៀបចំកម្មវិធីជួបជុំ ដោយសហភាពសហជីពចំនួន ២៤ សម្ព័ន្ធសហជីព អង្គការសង្គមស៊ីវិល និងដៃគូសង្គម ដែលមានអ្នកចូលរួមសរុបប្រមាណ ៤ ៦០០នាក់ ព្រមទាំងមានការប្រគល់ញត្តិជូនតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តំណាងរដ្ឋសភា និងតំណាងខុទ្ទកាល័យសម្តេចធិបតី។

ជារួម ការប្រារព្ធខួបអនុស្សាវរីយ៍លើកទី១៣៩ នៃទិវាពលកម្មអន្តរជាតិ ១ឧសភា ឆ្នាំនេះ បានប្រព្រឹត្តទៅដោយបរិយាកាសរីករាយស្និទ្ធស្នាល និងមានការចូលរួមកាន់តែសកម្មនិងផុសផុលពីគ្រប់ភាគីពាក់ព័ន្ធ ក្រោមម្លប់សុខសន្តិភាពនៅកម្ពុជា ដែលបាននាំមកនូវស្ថិរភាពអាជីវកម្ម សុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ អធ្យាស្រ័យល្អរវាងកម្មករនិយោជិតនិងនិយោជក ប្រសិទ្ធភាពនៃយន្តការត្រីភាគី ការលើកកម្ពស់សេរីភាពអង្គការវិជ្ជាជីវៈ លក្ខខណ្ឌការងារកាន់តែល្អប្រសើរ យន្តការដោះស្រាយវិវាទការងារកាន់តែមានភាពប្រសិទ្ធភាពដោយឈរលើគោលការណ៍ច្បាប់ជាធរមានរបស់កម្ពុជា និងបទដ្ឋានអន្តរជាតិខាងការងារ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមបងប្អូនកម្មករនិយោជិត និយោជក និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៥